ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយ និង យុទ្ធសាស្ត្រ
# ស្តីពីការផ្តល់ប្រឹក្សា ធ្វើតេស្តឈាមរក
# មេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់

## Policy and Strategy for HIV Counseling and Testing

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

ខែមករា ឆ្នាំ ២០០៧

# **អារម្ភកថា**

សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ផ្តល់នូវពត៌មានត្រឹមត្រូវនិងគ្រប់ជ្រុងជ្រោយអំពីមេរោគអេដស៍/ជំងឺអេដស៍និងជាច្រកចូលនៃសេវាបង្ការថែទាំព្យាបាលនិងសេវាគាំទ្រ ។ ការផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយ ស្ម័គ្រចិត្ត និងរក្សាការសំងាត់ផ្តល់ពត៌មានអំពីស្ថានភាព និងការប្រឈមមុខទៅនឹងការឆ្លងមេរោគអេដស៍/ ជំងឺអេដស៍។ ក្រសួងសុខាភិបាលតាមរយៈមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានរៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងគោលការណែនាំស្តីពីការផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវបានរៀបចំឡើង និងអនុម័តដោយក្រសួងសុខាភិបាលនៅឆ្នាំ ១៩៩៥ និងបានបង្កើតមណ្ឌលផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ដំបូងនៅឆ្នាំ ១៩៩៥ ។ គោលនយោបាយនេះ ត្រូវបានកែសំរួលដោយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអនុម័តជាថ្មីដោយក្រសួងសុខាភិបាលនៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០០២ ។ ដោយសារ មានការវិវត្តន៍ផ្នែក វិទ្យាសាស្ត្រវេជ្ជសាស្ត្រ និង សង្គម និងតាមរយៈបទពិសោធន៏ ជាក់ស្តែងស្តីពីការអនុវត្តន៏ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ និងដើម្បីឆ្លើយតបទៅនឹងតំរូវការនាពេលបច្ចុប្បន្ន គោលនយោបាយ និងយុទ្ធសាស្ត្រនេះត្រូវបានរៀបចំធ្វើការកែសំរួលជាថ្មីដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង ជំងឺអេដស៍ សើស្បែក និងកាមរោគសហការណ៏ជាមួយអង្គការជាតិ និង អន្តរជាតិជាដៃគូ ។ គោលនយោបាយនេះ គឺជាមគ្គុទ្ទេសក៏មួយដ៏សារៈសំខាន់សំរាប់អ្នកគ្រប់គ្រងកម្មវិធី និងបុគ្គលិកក្នុងការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ។

**ថ្ងៃទី ...ខែ.......ឆ្នាំ ២០០៧**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់ផ្នែកផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិង កាមរោគដែលបានដឹកនាំរៀបចំការពិនិត្យ និងកែសំរួលលើគោលនយោបាយនិងយុទ្ធសាស្ត្រស្តីពីការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់និងជាពិសេសដល់ក្រុមការងារដែលមានសមាជិកសមាជិកានៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការនានា ដូចជា អង្គការ UNICEF, WVC, FHI, US-CDCGAP, RHAC, USAID-HSSC និងដៃគូ ដ៏ទៃទៀតដែលបានរួមចំណែក និងយកចិត្តទុកដាក់ និង ចំណាយពេលវេលាក្នុងការពិនិត្យនិងកែ សំរួលលើគោលនយោបាយ និង យុទ្ធសាស្ត្រស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ដោយបានពិនិត្យដោយយកចិត្តទុកដាក់នូវរាល់ ចំនុច និង បញ្ចូលបន្ថែម នូវយុទ្ធសាស្ត្រសំខាន់ៗ ទៅ តាមតំរូវការ និងការអនុវត្តន៍ជាក់ស្តែងនៃសេវាផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់នៅក្នុងព្រះរាជាណាចក្រក្នុងពេលបច្ចុប្បន្ននេះ។
មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគសង្ឃឹមថាគោលនយោបាយ និងយុទ្ធសាស្ត្រនេះគឺជាមគ្គុទេសក៏ដ៏សំខាន់សំរាប់អនុវត្តក្នុងការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ទាំងផ្នែកសាធារណៈនិងឯកជន។

ថ្ងៃទី................ខែ...........................ឆ្នាំ ២០០៧

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍

សើស្បែក និងកាមរោគ

**វេជ្ជ. មាន ឈីវុន**

# មាតិកា


ទំព័រ

១. ប្រវត្តិ ៥

២. ហេតុផលនៃសេវា

៣. គោលបំណង ៧

៤. គោលនយោបាយសំរាប់ការធ្វើតេស្តឈាមរកមេរោគអេដស៍ ៧

- ការយល់ព្រមជាមុន និងការគោរពសិទ្ធិអតិថិជន
- ការលើកទឹកចិត្តអោយទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ នៅក្នុងមូលដ្ឋានសុខាភិបាល
- ការពង្រីកសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់
- ការធ្វើតេស្តឈាមរកមេរោគអេដស៍
- ពិធីសារការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការ សំងាត
- ការត្រួតពិនិត្យគុណភាពសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម
- ការបង្ការការឆ្លងរោគជាសកល

## ១. ប្រវត្តិ

គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់បានអនុម័តដោយក្រសួងសុខាភិបាលតាំងពីឆ្នាំ ១៩៩៥ ។ ដោយយោងទៅតាមការកើនឡើងនូវតំរូវការចាំបាច់នៃសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការ សំងាត់ និងការជឿនលឿនផ្នែកវិទ្យាសាស្ត្រវេជ្ជសាស្ត្រ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគបានរៀបចំកែសំរួលគោលនយោបាយ និងយុទ្ធសាស្ត្រនេះលើកទី ១ នៅខែកញ្ញាឆ្នាំ ២០០១ និងលើកទី២ នៅខែតុលាឆ្នាំ ២០០៦។ ក្រសួងសុខាភិបាលទទួលខុសត្រូវក្នុងការពង្រឹង ការអនុវត្តន៍ គោលនយោបាយ និងយុទ្ធសាស្ត្រ និងពិធីសារ ធ្វើតេស្តឈាមរកមេរោគអេដស៍ នៅក្នុងសេវាសាធារណៈ និងឯកជន និងតាមរយៈការបង្កើតប្រព័ន្ធត្រួតពិនិត្យតាមដាន និងប្រព័ន្ធធានាគុណភាពលើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគ អេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់។

មណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ដំបូងបង្អស់បានបង្កើត ឡើងក្នុងឆ្នាំ ១៩៩៥ នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ។ រហូតដល់ឆ្នាំ ២០០០ មានតែមណ្ឌល ផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់សរុបចំនួន៧ កន្លែងត្រូវបានបង្កើតឡើង ដែលមាន មួយកន្លែង នៅគ្លីនិកជាតិសើស្បែកនិងកាមរោគមួយនៅមន្ទីរពេទ្យព្រះបាទនរោត្តមសីហនុមួយនៅផ្នែកជំងឺឆ្លងនៃមន្ទីរសុខាភិបាលខេត្តកំពង់ចាមមួយនៅផ្នែកជំងឺឆ្លងនៃមន្ទីរ សុខាភិបាលខេត្តបាត់ដំបង មួយនៅមណ្ឌល១ ទីរួម ខេត្តសៀមរាប និងមួយទៀតនៅមន្ទីរពេទ្យបង្អែកក្រុងព្រះសីហនុ ។ នៅខែធ្នូ ឆ្នាំ ២០០៦ នេះ មានមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ចំនួន១៥០កន្លែងត្រូវបានបង្កើតឡើងជាស្រេចនៅទូទាំងខេត្តក្រុង ។ ការធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងគោលបំណងធ្វើ រោគវិនិច្ឆ័យ ត្រូវបានអនុវត្តនៅតាម មន្ទីរពេទ្យជាតិ និង មន្ទីរបង្អែក (ថ្នាក់ខេត្ត ក្រុង) នៅក្នុង ព្រះរាជាណាចក្រកម្ពុជា។ អង្គការក្រៅរដ្ឋាភិបាល នៅភ្នំពេញក៏ដូចជា នៅតាមបណ្តាខេត្តបានផ្តល់សេវា ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការ សំងាត់។

## ២. ហេតុផលនៃសេវា :

ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងយុទ្ធសាស្ត្របង្ការ និងថែទាំព្យាបាលជំងឺអេដស៍ ឈរលើហេតុផលជាច្រើនយ៉ាង ដូចខាងក្រោម:

- សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់អាចកាត់បន្ថយការចំលងមេរោគអេដស៍គួរអោយកត់សំគាល់តាមរយៈការបន្ថយការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់ទៅនឹងការឆ្លងមេរោគអេដស៍ ។

- ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍អាចជួយបុគ្គលទាំងឡាយអោយទទួលបាននូវសេវាវេជ្ជសាស្ត្រ និងសេវាសង្គមបានសមស្រប ។
- ការផ្តល់ប្រឹក្សា គឺជាផ្នែកមួយយ៉ាងសំខាន់នៃសេវាចិត្តសាស្ត្រសង្គម និងបានចាត់ទុកថាជាផ្នែកមួយនៃកម្មវិធីថែទាំអ្នកជំងឺតាមផ្ទះ និងតាមសហគមន៍ ដែលត្រូវផ្តល់អោយអ្នកជំងឺក៏ដូចជាការថែទាំក្នុងមន្ទីរពេទ្យ និងក្នុងមណ្ឌលថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺ អេដស៍ផងដែរ ។
- ការធ្វើតេស្តរកមេរោគអេដស៍គឺជាមធ្យោបាយមួយដ៏សំខាន់សំរាប់ធ្វើរោគវិនិច្ឆ័យដែលជាជំនួយដល់ការថែទាំព្យាបាលក្នុងមន្ទីរពេទ្យ និងតាមគ្លីនិក ។
- ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍មានសារៈសំខាន់ជាពិសេសចំពោះកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ។
- ការធ្វើតេស្តរកមេរោគអេដស៍ជាផ្នែកមួយយ៉ាងសំខាន់សំរាប់ប្រព័ន្ធនៃការអង្កេតឈាម និងស្រាវជ្រាវ ។

បែបបទនៃការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ទាំងអស់នេះទាមទារអោយមានការយកចិត្តទុកដាក់ ជាពិសេសចំពោះច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ (ជំពូកទី៤) ក្រមសីលធម៌វេជ្ជសាស្ត្រ និងការធានាគុណភាពនៃការធ្វើតេស្តឈាមរកមេរោគអេដស៍ ។ ការរក្សាការសំងាត់ និងការផ្តល់នូវសេចក្តីមេត្តាករុណា គឺជាមូលដ្ឋាននៃការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ ។

## ៣. <u>គោលបំណង:</u>

- ដើម្បីគាំទ្រដល់ការពង្រីក និងពង្រឹងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ក្នុងផ្នែកសុខភាពសាធារៈ និងឯកជន ។
- ដើម្បីធានាថាការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ទាំងផ្នែកសុខភាពសាធារណៈ និងឯកជនបានអនុវត្តត្រឹមត្រូវតាមគោលនយោបាយ គោលការណ៍ណែនាំ និងវិធីសាររបស់ថ្នាក់ជាតិ ។
- ដើម្បីធានានូវគុណភាពសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ។

- ដើម្បីធានាថា អតិថិជនទទួលបានពត៌មាន ការលើកទឹកចិត្ត អោយប្រើប្រាស់សេវាផ្តល់ ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ និងលើកទឹកចិត្តអោយប្រើប្រាស់សេវាបង្ការ និងថែទាំ និងព្យាបាលជំងឺអេដស៍ ។

## គោលនយោបាយសំរាប់ធ្វើតេស្តរកមេរោគអេដស៍

គោលនយោបាយ និង យុទ្ធសាស្ត្រ ស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ និងរក្សាការសំងាត់នេះ បានរៀបចំឡើងដោយផ្អែកលើច្បាប់ និងគោលការណ៍ណែនាំ អនុវត្តច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការ រីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដូចខាងក្រោមនេះ :

- ការយល់ព្រមជាមុននិងការគោរពសិទ្ធិអតិថិជន
- ការលើកទឹកចិត្តអោយទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយ ស្ម័គ្រចិត្ត និងរក្សាការសំងាត់ នៅក្នុងមូលដ្ឋានសុខាភិបាល ។
- ការពង្រីកសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់
- ការធ្វើតេស្តឈាមរកមេរោគអេដស៍ ។
- ពិធីសារការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការ សំងាត់
- ការត្រួតពិនិត្យគុណភាពសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម
- ការបង្ការការឆ្លងរោគជាសកល

### គោលនយោបាយ ១

### ការយល់ព្រមជាមុន និងការគោរពសិទ្ធិអតិថិជន

ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ជាយុទ្ធសាស្ត្រមួយក្នុងការបង្ការថែទាំ និង ព្យាបាលមេរោគអេដស៍និងជំងឺអេដស៍ ។ បញ្ហាជាច្រើនដែលទាក់ទងទៅនឹងមេរោគអេដស៍ដូចជាការម៉ាក់ងាយ និងការរើសអើងជាដើម ។ ដើម្បីជៀសវាងបញ្ហាទាំងនេះ ការគោរពសិទ្ធអតិថិជនជាការសំខាន់ក្នុងការ ធ្វើតេស្តរកមេរោគអេដស៍ ។

**យុទ្ធវិធីចំបងៗ ដើម្បីអនុវត្តគោលនយោបាយទី ១**

១.១. ការធ្វើតេស្តឈាមរកមេរោគអេដស៍ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និង ត្រូវមានការយល់ព្រមជាមុនពីសាម៉ីជនផ្ទាល់ ។ ចំពោះសាម៉ីជនជាអនីតិជន ការធ្វើតេស្តរកមេរោគអេដស៍ គឺតម្រូវអោយមានការយល់ព្រមជាលាយល័ក្ខអក្សរពីអាណាព្យាបាលស្របច្បាប់ ។ បើការយល់ព្រមជាលាយល័ក្ខអក្សរពីអាណាព្យាបាលស្របច្បាប់ ពុំអាចធ្វើបាន ការធ្វើតេស្តឈាមរកមេរោគអេដស៍អាចប្រព្រឹត្តទៅបានដោយគ្រាន់តែមានការព្រមព្រៀងពីអនីតិជនប្រសិនបើការធ្វើតេស្តនេះផ្តល់អត្ថ-ប្រយោជន៍ផ្ទាល់ចំពោះអនីតិជន ជាពិសេស ចំពោះ អនិតិជនដែលមាន ការប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍ ។

១.២. ចំពោះជនវិកលចរិត ការធ្វើតេស្តឈាមរករោគអេដស៍ត្រូវមានការយល់ព្រមជាមុនពីអាណាព្យាបាល ។ ក្នុងករណីគ្មានអាណាព្យាបាល អ្នកផ្តល់សេវាអាចធ្វើការសំរេចចិត្ត ប្រសិនបើមានការចាំបាច់ ។

១.៣. ហាមដាច់ខាតចំពោះការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយដាក់លក្ខខ័ណ្ឌ ( Compulsory testing ) ដូចជាការធ្វើតេស្តឈាមរកមេរោគអេដស៍ មុន និងក្រោយការអនុញ្ញាតអោយចូលបំរើការងារ ចូលសិក្សានៅក្នុងគ្រឹះស្ថានសិក្សានានា ក៏ដូចជាសំរាប់ការអនុវត្តសេរីភាពស្នាក់នៅ សិទ្ធិធ្វើដំណើរ ឬសេវាកម្មផ្សេងៗ ។

១.៤. ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយបង្ខំ (Mandatory testing) ត្រូវអនុញ្ញាតិតែក្នុងករណីមានសេចក្តីបង្គាប់របស់តុលាការ ។

## គោលនយោបាយ ២

## ការលើកទឹកចិត្តអោយទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាតនៅក្នុងមូលដ្ឋានសុខាភិបាល

ដើម្បីជំរុញអោយមានការប្រើប្រាស់សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ទាមទារអោយមានការលើកទឹកចិត្តអតិថិជននៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន ។

### យុទ្ធវិធីចំបងៗ ដើម្បីអនុវត្តគោលនយោបាយទី ២

២.១. ការផ្តួចផ្តើមគំនិតដោយអ្នកផ្តល់សេវាសុខាភិបាលដើម្បីផ្តល់ពត៌មានដល់អ្នកជំងឺមកទទួលសេវានានាអោយបានដឹងនិងលើកទឹកចិត្តអោយទទួលសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ( Provider Initiated Testing and Counseling) ។ រាល់អតិថិជនដែលមករកសេវាសុខភាពនានា អ្នកផ្តល់សេវាត្រូវលើកទឹកចិត្ត និងផ្តល់ពត៌មានពីសេវាធ្វើផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ជូនអតិថិជនហើយបញ្ជូនទៅសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ប្រសិនបើគាត់ស្ម័គ្រចិត្ត ។

២.២. ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍បានអនុវត្តរាល់ស្ត្រីមានផ្ទៃពោះដែលមកទទួលសេវានៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកតាមរយៈកម្មវិធីការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន（PMTCT）។

២.៣. បុគ្គលិកមណ្ឌលសុខភាពដែលទទួលបន្ទុកសកម្មភាព TB-DOTS និងបុគ្គលិកសេវាព្យាបាលជំងឺរបេងនៃមន្ទីរពេទ្យបង្អែកឬអតីតមន្ទីរពេទ្យស្រុកត្រូវផ្តល់ប្រឹក្សា និងបញ្ជូនអ្នកជំងឺរបេងតាមការស្ម័គ្រចិត្តទៅធ្វើតេស្តឈាមរកមេរោគអេដស៍នៅ មណ្ឌលផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ (VCCT) ដែលនៅ ជិតនោះ ។

## គោលនយោបាយ ៣

## ការពង្រីកសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់

យោងតាមផែនការយុទ្ធសាស្ត្រដើម្បីបង្ការការរាលដាលជំងឺអេដស៍ - ជំងឺកាមរោគ និងថែទាំអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍និងជំងឺកាមរោគ ឆ្នាំ ២០០៤-២០០៧ ។ យុទ្ធសាស្ត្រទី៦ដែលមានបំណងពង្រឹង និងពង្រីកសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ទាំងផ្នែកសាធារណៈ និងឯកជនមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ នឹងពង្រីកមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់អោយបានគ្រប់ខេត្ត-ក្រុង ទាំងអស់ ។

**យុទ្ធវិធីចំបងៗដើម្បីអនុវត្តគោលនយោបាយទី ៣:**

**៣.១. ផ្សព្វផ្សាយគោលនយោបាយ និងយុទ្ធសាស្ត្រ សំរាប់ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍** គោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវធ្វើការផ្សព្វផ្សាយដល់ផ្នែកពាក់ព័ន្ធបន្ទាប់ពីការកែសំរួល និងអនុមតិដោយក្រសួងសុខភិបាល ។

**៣.២. ពង្រឹង និងពង្រីកសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់**៖មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគបានបង្កើតមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ចំនួន ១៥០ កន្លែងត្រឹមខែធ្នូ ឆ្នាំ២០០៦ ។ មជ្ឈមណ្ឌលជាតិ និងបន្តពង្រីកសេវានេះបន្ថែមទៅកន្លែងដទៃទៀតនៅទូទាំងប្រទេស ។ មជ្ឈមណ្ឌលជាតិក៏បានពង្រឹងគុណភាពសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ដោយផ្អែកលើនិយាមនៃបែបបទសំរាប់អនុវត្តសកម្មភាព (SOP) ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល ។

**៣.៣. បង្កើត និងផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលសំរាប់ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់** ដើម្បីបង្កើនសមត្ថភាពបុគ្គលិកសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគបានរៀបចំចងក្រងកម្មវិធីបណ្តុះបណ្តាលសំរាប់ការបណ្តុះបណ្តាលស្តីពីការផ្តល់ប្រឹក្សា និងធ្វើ តេស្ត ឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់នៅឆ្នាំ ២០០៤ និង ធ្វើការកែសំរួលនៅឆ្នាំ ២០០៧ ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ កំពុងរៀបចំចងក្រងសៀវភៅបណ្តុះបណ្តាលសំរាប់ការធ្វើតេស្តឈាមរកមេរោគអេដស៍ ។ បទពិសោធន៍ទាំងឡាយដែលបានមកពីការ អនុវត្តន៍ នឹងត្រូវដកស្រង់បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពីការផ្តល់ប្រឹក្សាអោយសមស្របទៅតាមវប្បធម៌បទពិសោធន៍ និងតំរូវការក្នុងប្រទេសកម្ពុជា ។ ឯកសារកម្មវិធីបណ្តុះបណ្តាលនេះអាចនឹងត្រូវកែ សំរួលឡើងវិញបើមានភាពចាំបាច់ ។

**៣.៤. ចលនាធនធានសំរាប់បង្កើត និងដំណើរការមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់** ដើម្បីធានាសកម្មភាព និងដំណើរការសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និង កាមរោគបានរៀបចំ ផែនការសកម្មភាពជារៀងរាល់ឆ្នាំសំរាប់កម្មវិធីអេដស៍ទូទាំង ២៤ ខេត្ត-ក្រុង ដោយផ្តល់អនុសាសន៍អោយដាក់បញ្ចូលថវិកាជាតិ និងថវិការបស់ដៃគូនានាដែលមានសកម្មភាពនៅក្នុង ខេត្ត-ក្រុង

របស់ខ្លួន ។ មន្ទីរសុខាភិបាលខេត្ត-ក្រុងត្រូវរៀបចំផែនការដើម្បីបង្កើត និងអនុវត្តសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ មជ្ឈមណ្ឌលជាតិ នឹងជួយគាំទ្រ ក្នុងការស្វែងរកការឧបត្ថម្ភ តាមរយៈផែនការសកម្មភាពទាំងនោះ ។

**៣.៥. គាំទ្រដល់ការបង្កើត និងពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដាន និងការអភិបាលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ស្ម័គ្រចិត្តនិងរក្សាការសំងាត់** មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងការអភិបាលព្រមទាំងបានកែសំរួលនូវឧបករណ៍សំរាប់តាមដាន និងអភិបាល ដូចជារៀប ចំបង្កើត ជាបញ្ជីត្រួតពិនិត្យ (Supervision checklist) សំរាប់អ្នកអភិបាលថ្នាក់ខេត្ត-ក្រុងដើម្បីប្រើប្រាស់ក្នុងការត្រួតពិនិត្យតាមដាន និងការអភិបាលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់។ ប្រព័ន្ធនេះត្រូវប្រើប្រាស់ទាំងក្នុងសេវាសុខាភិបាលសាធារណៈ និងឯកជន និងត្រូវត្រួតពិនិត្យតាមដានដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។ មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹង ជំងឺអេដស៍ សើស្បែក និងកាមរោគបានពង្រឹងប្រព័ន្ធទិន្នន័យដោយរៀបចំអោយមានអ្នកគ្រប់គ្រងទិន្នន័យនិងរបាយការណ៍កម្មវិធីអេដស៍នៅតាមបណ្តា ខេត្ត-ក្រុង មួយចំនួន និងបន្តពង្រីកអោយបានគ្រប់ខេត្ត-ក្រុង។ មណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ទាំងសាធារណៈ និងឯកជនត្រូវផ្តល់របាយការណ៍ជាទៀងទាត់ទៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាលដោយប្រើប្រាស់ទំរង់របាយការណ៍គំរូដែលកំណត់ដោយមជ្ឈមណ្ឌលជាតិ។ ការត្រួតពិនិត្យគុណភាពលើការធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវធ្វើឡើងរាងរាល់ ៦ ខែ ឬមួយឆ្នាំម្តង។

**៣.៦. ប្រព័ន្ធបញ្ជូន**

យន្តការនៃការបញ្ជូនសំដៅយកការបញ្ជូនអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ទៅរកសេវាថែទាំ និង ព្យាបាលបន្តសំរាប់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងបញ្ជូនមកមណ្ឌលផ្តល់ប្រឹក្សាពីសេវានានាដើម្បធ្វើតេស្តរកមេរោគអេដស៍។ ដោយហេតុថាមានអតិថិជនជាច្រើនបានមកធ្វើតេស្តរកមេរោគអេដស៍មានការកើនឡើង និងមានការកើនឡើងនូវចំនួនអ្នកផ្ទុកមេរោគអេដស៍ចាំបាច់ត្រូវជួយឧបត្ថម្ភក្រុមគាំទ្រប្រព័ន្ធបញ្ជូនពីអង្គការក្នុងសហគមន៍។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគក៏បានភ្ជាប់ទំនាក់ទំនងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ជាមួយសេវាផ្សេងទៀតដូចជាសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន សេវាថែទាំព្យាបាលជំងឺរបេង សេវាថែទាំនិងព្យាបាលជំងឺឱកាសនិយម និងជំងឺអេដស៍ជាដើម។

ប្រព័ន្ធបញ្ជូនជំងឺអេដស៍ និងជំងឺរបេងត្រូវបានបង្កើតឡើងដើម្បីលើកស្ទួយ និងធានាដល់កម្មវិធីរបេងអេដស៍នៅព្រះរាជាណាចក្រកម្ពុជា។

**៣.៧.ការស្រាវជ្រាវបែបអនុវត្តន៍ ( Operational Research )**

ចាំបាច់ត្រូវធ្វើការសិក្សាជាច្រើនទៀតអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍នៅប្រទេសកម្ពុជាដើម្បីលើកស្ទួយដល់ការផ្តល់សេវាទាំងនេះ អោយសមស្របទៅតាមស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្ន។

## គោលនយោបាយ ៤

**ការធ្វើតេស្តឈាមរកមេរោគអេដស៍**

ដោយអនុលោមទៅតាមសេចក្តីថ្លែងការរួមរវាង UNAIDS និង WHO នៅឆ្នាំ 2004 ការធ្វើតេស្តឈាមរកមេរោគអេដស៍ ទទួលបានការអនុញ្ញាត នៅក្នុងស្ថានភាពដូចខាងក្រោម:

- សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់
- គោលបំណងធ្វើរោគវិនិច្ឆ័យ (នៅក្នុងគ្រឹះស្ថាននានា)
- ការស្រាវជ្រាវ/ ការអង្កេតរកមេរោគអេដស៍នៅក្នុងកម្មវិធីអង្កេតរបស់ក្រសួងសុខាភិបាល
- សុវត្ថិភាពឈាម ( Blood donor screening )

**យុទ្ធវិធីចំបងៗ ដើម្បីអនុវត្តគោលនយោបាយទី ៤**

**៤.១.ការធ្វើតេស្តឈាមរកមេរោគអេដស៍នៅក្នុងមណ្ឌលផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ :**

ទោះជានៅក្នុងស្ថាប័នរដ្ឋ ឬឯកជនក៏ដោយរាល់សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ត្រូវអនុវត្តតាមបែបបទខាងក្រោមនេះ :

- ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាល
- ការធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវធ្វើឡើងដោយស្ម័គ្រចិត្តនិងត្រូវមានការយល់ព្រមជាមុនពីសាម៉ីជនផ្ទាល់ ។
- រាល់ការធ្វើតេស្តឈាមរកមេរោគអេដស៍ ត្រូវតែមានការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តនិងក្រោយពេលធ្វើតេស្ត។

- បុគ្គលិកផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវមានសមត្ថភាពតាមបែបបទគំរូរបស់ក្រសួងសុខាភិបាល
- បែបបទនៃការធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវអនុលោមទៅតាមពិធីសាររបស់ក្រសួងសុខាភិបាល ។
- ត្រូវរក្សាការសំងាត់អោយបានខ្ជាប់ខ្ជួនរាល់លទ្ធផលតេស្តឈាមរកមេរោគអេដស៍

## ៤.២ ការធ្វើតេស្តរកមេរោគអេដស៍ក្នុងគោលបំណងធ្វើរោគវិនិច្ឆ័យ

ការធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងគោលបំណងធ្វើរោគវិនិច្ឆ័យដើម្បីជាជំនួយបច្ចេកទេសដល់គ្រូពេទ្យព្យាបាលក្នុងការធ្វើរោគវិនិច្ឆ័យ និងការគ្រប់គ្រងព្យាបាល ។ ចំពោះអ្នកជំងឺដែលមានរោគសញ្ញា ប្រហាក់ប្រហែល នឹងជំងឺអេដស៍រាប់បញ្ចូលទាំងអ្នកជំងឺរបេងសកម្មត្រូវបញ្ជូនមកមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ។ ទោះជាយ៉ាងណាក៏ដោយការធ្វើតេស្តឈាមរកមេរោគអេដស៍នេះ ត្រូវគោរពទៅតាម ឬ ប្រសិនបើ:

- អ្នកជំងឺអេដស៍អាចទទួលបាននូវគុណប្រយោជន៍ ដូចជាការថែទាំព្យាបាល ឬការបញ្ជូនទៅរកការព្យាបាលមួយដែលសមស្រប ។
- ត្រូវមានការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមរកមេរោគអេដស៍ និងមានការយល់ព្រមជាមុនពីអ្នកជំងឺ ។ ការផ្តល់លទ្ធផលតេស្តឈាមត្រូវមានការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត ។
- លទ្ធផលតេស្តត្រូវរក្សាការសំងាត់អោយបានហ្មត់ចត់និងអាចដឹងបានត្រឹមតែអ្នកផ្តល់ប្រឹក្សា និងបុគ្គលិកទទួលបន្ទុកការថែទាំអ្នកជំងឺប៉ុណ្ណោះដោយមានការរក្សាការសំងាត់យ៉ាងខ្ជាប់ខ្ជួនជូនអ្នកជំងឺ ។ គ្មានសមាជិកគ្រួសារអ្នកជំងឺណាម្នាក់ត្រូវទទួលដំណឹងអំពីការធ្វើតេស្ត ឬលទ្ធផលតេស្តឡើយលើកលែងតែមានការអនុញ្ញាតពីអ្នកជំងឺ ។

## ៤.១.៣. ការអង្កេតឈាមរកមេរោគអេដស៍នៅក្នុងកម្មវិធីអង្កេតរបស់ក្រសួងសុខាភិបាល

**( HSS)**

ការធ្វើតេស្តរកមេរោគអេដស៍អនាមិក (anonymous, unlinked testing) ក្នុងគោល បំណងស្រាវជ្រាវ ឬអង្កេត（Surveillance） ត្រូវមានការអនុម័តពីក្រសួងសុខាភិបាល និងត្រូវមានការអនុម័ត និងអនុលោមទៅតាមគោលការណ៍ក្រមសីលធម៌របស់គណ:កម្មាធិការជាតិ ពិនិត្យក្រមសីលធម៌ សំរាប់ការស្រាវជ្រាវសុខភាព ។

### ៤.១.៤. សុវត្ថិភាពឈាម (Blood donor screening)

យោងទៅតាមមាត្រា១៤នៃច្បាប់ស្ដីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដែលចែងថា" រាល់ការប្រើប្រាស់ឈាម ជាលិកា ឬ សរីរាង្គ ត្រូវធ្វើតេស្ដមេរោគអេដស៍ បញ្ជាក់ជាមុន" ។

## គោលនយោបាយ ៥

## ពិធីសារការផ្ដល់ប្រឹក្សា និងការធ្វើតេស្ដឈាមរកមេរោគអេដស៍

ដោយហេតុថាការធ្វើតេស្ដឈាមរកមេរោគអេដស៍អាចនាំមកនូវការម៉ាក់ងាយ និងការរើសអើងប្រឆាំងអ្នកផ្ទុកមេរោគអេដស៍អ្នកជំងឺអេដស៍ និងគ្រួសារការធ្វើតេស្ដឈាមចាំបាច់ត្រូវមានការគោរពនូវបែបបទមួយចំនួន។ បែបបទទាំងនេះមិនត្រឹមជួយផ្ដល់នូវទំនុកចិត្តពីអតិថិជនក៏ប៉ុន្តែជួនផ្ដល់នូវការរក្សាការសំងាត់ផ្ដល់នូវចំណេះដឹងស្ដីពីជំងឺអេដស៍ ការបង្ការ និងវិធីសាស្ត្រនានាសំរាប់ទប់ទល់នឹងការរើសអើង និងការម៉ាក់ងាយផងដែរ ។

## យុទ្ធវិធីចំបងៗ ដើម្បីអនុវត្តគោលនយោបាយទី ៥

### ៥.១. បែបបទដើម្បីធានាការរក្សាការសំងាត់

- ត្រូវធានាភាពជាឯកជនដល់អតិថិជនដោយមានបន្ទប់ផ្ដល់ប្រឹក្សាតាមបែបបទដែលមានភាពរក្សាការសំងាត់
- ត្រូវផ្ដល់ប័ណ្ណវិភាគមានចុះលេខកូដសំងាត់ដល់អតិថិជនដោយអ្នកផ្ដល់ប្រឹក្សា
- ការបូមឈាមគួរប្រព្រឹត្តទៅនៅក្នុងបន្ទប់ផ្ដល់ប្រឹក្សាដោយអ្នកផ្ដល់ប្រឹក្សា ហើយឈាម និងប័ណ្ណវិភាគត្រូវបញ្ជូនទៅមន្ទីរពិសោធន៍
- បន្ទាប់ពីការធ្វើតេស្ដឈាមរួច បុគ្គលិកមន្ទីរពិសោធន៍ត្រូវកត់ត្រាលទ្ធផលតេស្ដនៅក្នុងប័ណ្ណវិភាគ ហើយដាក់ក្នុងស្រោមសំបុត្របិទជិតចុះតែលេខសំងាត់ប៉ុណ្ណោះហើយបញ្ជូនទៅអ្នកផ្ដល់ប្រឹក្សាដែលត្រូវផ្ដល់ជូនអតិថិជន ។

យោងតាម ច្បាប់ ស្ដីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគ អេដស៍/ ជំងឺអេដស៍ ការរក្សាភាពសំងាត់ត្រូវបានលើកលែងតែក្នុងករណីៈ

- ផ្ដល់ព័ត៌មានដល់បុគ្គលិកសុខាភិបាលដែលធ្វើការព្យាបាលឬថែទាំអ្នកមានមេរោគអេដស៍/ជំងឺអេដស៍

- ឆ្លើយតបទៅនឹងដីកាចេញដោយតុលាការ

### ៩.២. ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមរកមេរោគអេដស៍

ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមត្រូវមានៈ

- ការពិភាក្សាអំពីហេតុផលដែលអតិថិជនសុំធ្វើតេស្តឈាមរកមេរោគអេដស៍
- វាយតំលៃការយល់ដឹងរបស់អតិថិជន អំពីព័តិមានទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍
- ពិភាក្សា និងវាយតំលៃការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍របស់អតិថិជន
- ពិភាក្សាអំពីជំរើសត្រឹមត្រូវ និងផែនការកាត់បន្ថយការប្រឈមមុខរបស់អតិថិជន
- ពន្យល់អតិថិជនអំពីអត្ថន័យនិងអ្វីៗដែលអាចកើតមានឡើងដោយសារលទ្ធផលវិជ្ជមានអវិជ្ជមាន និងរយៈពេលចំហរ
- ពន្យល់ពីគុណសម្បត្តិ ការធ្វើតេស្តរកមេរោគអេដស៍

### ៩.៣. ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមរកមេរោគអេដស៍

ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមរកមេរោគអេដស៍ធ្វើឡើងនៅពេលអតិថិជនមកទទួលលទ្ធផលតេស្តឈាម។ ហាមដាច់ខាតក្នុងការប្រាប់លទ្ធផលតេស្តឈាមដល់អតិជនតាមរយៈទូរស័ព្ទតាមសំបុត្របូដោយគ្មានការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត ។ ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តសំដៅលើ :

**លទ្ធផលតេស្តអវិជ្ជមាន**

- បញ្ជាក់ប្រាប់ពីលទ្ធផលតេស្ត និងពិភាក្សាអត្ថន័យអវិជ្ជមាននិងអ្វីៗដែលកើតមានឡើងដោយសារលទ្ធផលតេស្ត ។
- ពិភាក្សាលទ្ធផលតេស្ត និងសង្ខេបផែនការកាត់បន្ថយការប្រឈមមុខរបស់អតិថិជនដោយមានការគាំទ្រផ្លូវចិត្តពីអ្នកផ្តល់ប្រឹក្សា ។
- រៀបចំផែនការសំរាប់ធ្វើតេស្តម្តងទៀតតាមពេលវេលាសមស្រប ។

**លទ្ធផលតេស្តវិជ្ជមាន**

- បញ្ជាក់ប្រាប់ពីលទ្ធផលតេស្ត និងអត្ថន័យវិជ្ជមាន
- ធានាអះអាងថាអតិថិជនមានលទ្ធភាពដោះស្រាយស្ថានភាពរបស់ខ្លួន ។
- ពិភាក្សាអំពីអារម្មណ៍ និងការរំជួលចិត្តរបស់អតិថិជន

- គាំទ្រផ្លូវចិត្តរបស់អតិថិជន
- ពិភាក្សាអំពីអ្វីដែលអាចកើតមានឡើងដល់អតិថិជនដោយលទ្ធផលតេស្តរបស់គាត់
- ពិភាក្សាអំពីក្តីកង្វល់ និងការភ័យខ្លាចរបស់អតិថិជន
- ស្វែងរក និងផ្តល់ប្រឹក្សាអំពីរបៀបដោះស្រាយបញ្ហាចំពោះមុខភ្លាមៗ និងជាក់ស្តែង
- ផ្តល់ប្រឹក្សាអំពីការរស់នៅ និងដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងជំងឺ
- ផ្តល់ព័ត៌មានអំពីការថែរក្សាអោយមានសុខភាពល្អ
- ផ្តល់ព័ត៌ ឬបញ្ជូនទៅសេវាថែទាំព្យាបាល សេវាផ្តល់ប្រឹក្សា សេវាឧបត្ថម្ភ ក្រុមគាំទ្រអ្នកជំងឺអេដស៍ និងប្រភពធនធានដ៏ទៃទៀតដែលអាចជួយអតិថិជន ។

**៩.៤.ការផ្តល់ប្រឹក្សាគាំទ្រ**

ក្នុងករណីលទ្ធផលតេស្តវិជ្ជមានត្រូវមានការផ្តល់ប្រឹក្សាគាំទ្របន្តបន្ទាប់បន្ថែមទៀត។ ការផ្តល់ប្រឹក្សាគាំទ្រមានសារៈសំខាន់ណាស់ក្នុងការជួយអតិថិជនអាចដោះស្រាយនូវស្ថានភាពផ្សេងៗបាន ។ អ្នកផ្តល់ប្រឹក្សាត្រូវបញ្ជូនអតិថិជនដែលលទ្ធផលតេស្តវិជ្ជមានទៅក្រុមថែទាំតាមផ្ទះ ឬ សេវាព្យាបាលបន្តដែលនៅជិតនោះ ។

**៩.៥. ពិធីសារ និងប្រតិករធ្វើតេស្តឈាមរកមេរោគអេដស៍**

**៩.៥.១. បែបផែននៃការធ្វើតេស្តរកមេរោគមេរោគអេដស៍**

នៅប្រទេសកម្ពុជាពិធីសារធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដូចគ្នា នឹងពិធីសារធ្វើតេស្តរកមេរោគអេដស៍ដើម្បីរករោគវិនិច្ឆ័យដែរ។

មានបែបផែននៃការធ្វើតេស្តតាមប្រតិករដែលបានអនុម័តដោយក្រសួងសុខាភិបាល:

១. បែបបទទី១: ធ្វើតេស្ត Determine ជាតេស្តទី១ និង តេស្ត UniGold or Stat-Pak ជាតេស្តបញ្ជាក់។

២. បែបបទទី២: ធ្វើតេស្ត Serodia (PA) ជាតេស្តទី១ និង តេស្ត Determineជាតេស្តបញ្ជាក់។

៣. បែបបទទី៣:ធ្វើតេស្ត ELISA(Genscreen) ជាតេស្តទី១ និង តេស្ត Determine ជាតេស្តបញ្ជាក់ ។

**៩.៥.២. ពិធីសារធ្វើតេស្តឈាមរកមេរោគអេដស៍**

**វិធីសានេះបង្ហាញដូចខាងក្រោម:**

រាល់សេរ៉ូម ឬ ផ្លាស្មាត្រូវធ្វើតេស្តលើកទី១ដោយតេស្តធម្មតា ឬតេស្តរហ័ស ( Simple/rapid assay):

- សេរូមឈាមដែលគ្មានប្រតិកម្មក្នុងពេលធ្វើតេស្តលើកទី១ត្រូវចាត់ទុកថាពុំមានអង្គបដិបក្ខប្រាណប្រឆាំងមេរោគអេដស៍
- សេរ៉ូមឈាមដែលធ្វើតេស្តលើកទីមួយត្រូវធ្វើតេស្តឡើងវិញម្តងទៀតដោយប្រើប្រាស់តេស្តរហ័ស ឬធម្មតាផ្សេងទៀត (ដែលខុសពីតេស្តទី១) ឬ ELISA.
- សេរ៉ូមឈាមប្រតិកម្មក្នុងពេលធ្វើតេស្តទាំងពីរលើកត្រូវចាត់ទុកថាមានអង្គបដិបក្ខប្រាណប្រឆាំងនឹងមេរោគអេដស៍
- សេរ៉ូមឈាមប្រតិកម្មក្នុងពេលធ្វើតេស្តទី១ ប៉ុន្តែមិនប្រតិកម្មក្នុងពេលធ្វើតេស្ត លើកទី ២ ត្រូវធ្វើតេស្តទាំងពីរនេះសារឡើងវិញដោយប្រើសេរ៉ូមឈាមដដែល ។
- លទ្ធផលស្របគ្នាក្នុងពេលធ្វើតេស្តឡើងវិញនេះបញ្ជាក់ពីលទ្ធផលវិជ្ជមាន ឬអវិជ្ជមាន។
- ប្រសិនបើលទ្ធផលទាំងពីរលើកនៅតែផ្ទុយគ្នាត្រូវចាត់ទុកថាលទ្ធផលមិនអាចកំណត់បានត្រូវបូមឈាមសារជាថ្មីដើម្បីធ្វើតេស្តសារឡើងវិញក្នុងរយះពេល១៥ ថ្ងៃបន្ទាប់។
- ប្រសិនបើក្រោយ១៥ថ្ងៃ លទ្ធផលនៅតែផ្ទុយគ្នាត្រូវបញ្ជូនសំនាកឈាមទៅមន្ទីរពិសោធន៍បង្អែកដែលជិតបំផុត ។

**៥.៥.៣. តេស្តរហ័ស** (Repid Test)

តេស្តធម្មតាឬតេស្តរហ័សដែលប្រើប្រាស់ត្រូវទទួលស្គាល់និងយល់ព្រមដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យោងតាមស្តង់ដាររបស់អង្គការសុខភាពពិភពលោក WHO ។

## គោលនយោបាយ ៦

### ការត្រួតពិនិត្យគុណភាពសេវាផ្តល់ប្រឹក្សានិងការធ្វើតេស្តរកមេរោគអេដស៍

ដើម្បីធានាថាសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ផ្តល់ដល់អតិថិជនប្រកបដោយគុណភាពមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខា ភិបាលទទួលខុសត្រូវក្នុងការពិនិត្យគុណភាពលើសេវាធ្វើតេស្តឈាមរកមេរោគ អេដស៍ទាំងផ្នែក សាធារណៈនិងឯកជន ដោយមានរៀបចំការបណ្តុះបណ្តាល ប្រកបដោយគុណភាពតាមស្តង់ដារ របស់ក្រសួងសុខាភិបាលរៀបចំ ហេដ្ឋារចនាសម្ព័ន្ធសមស្រប

និងមានភាពសំងាត់ និង ផ្តល់ តេស្តឃីត (HIV Test Kits) ដែលទទួលស្គាល់ និងយល់ព្រមដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យោងតាមស្តង់ដាររបស់អង្គការសុខភាពពិភពលោក WHO ។

### យុទ្ធវិធីចំបងៗ ដើម្បីអនុវត្តគោលនយោបាយទី ៦

៦.១. **មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគត្រូវរៀបចំអោយមាន :**

- ការត្រួតពិនិត្យគុណភាពការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយមានការត្រួតពិនិត្យពីមន្ទីរពិសោធជាតិ ។
- ការធានាគុណភាពតាមរយៈការប្រជុំបណ្តុញតាមតំបន់ខេត្តក្រុងដើម្បីផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក ។
- ការអភិបាលពីថ្នាក់ជាតិ និងថ្នាក់ខេត្ត លើការ ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម រកមេរោគអេដស៍

៦.២. **ការរក្សាទុកប្រតិករ** (Reagent storage)

ដើម្បីរក្សាគុណភាពប្រតិករ ទាមទារអោយរក្សាទុកក្នុងសីតុណ្ហភាព កំរិតពី ២-២៨ អង្សារសេ ។ ក្នុងករណីដែលការផ្គត់ផ្គង់ថាមពលអគ្គិសនីមានការខ្វះខាត ជាពិសេសនៅតាមជនបទដាច់ស្រយ៉ាល ប្រធានមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកប្រធានការិយាល័យស្រុកប្រតិបត្តិ និងប្រធានសុខាភិបាលខេត្តត្រូវជួយសំរបសំរួលលើកការទុកដាក់ប្រតិករនេះ ។

៦.៣. **ការរក្សាទុកសំណាកឈាមវិជ្ជមាន** (positive specimen)

នាបច្ចុប្បន្ន ការត្រួតពិនិត្យ និងការធ្វើតេស្តឈាមឡើងវិញ ត្រូវធ្វើឡើងតាមនីតិវិធីផ្សេងពីមុនដោយមានការបញ្ជូនសំណាកឈាម Sample ពី មន្ទីរពិសោធន៍ថ្នាក់ជាតិទៅមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ហេតុនេះមិនចាំបាច់អោយមានការរក្សាទុកដាក់ឈាមវិជ្ជមាននោះទេ ។

## គោលនយោបាយ ៧

### ការបង្ការការចំលងមេរោគអេដស៍នៅមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់

ការប្រុងប្រយ័ត្នជាសកល គឺជាវិធានការណ៍ដ៏សាមញ្ញសំរាប់បង្ការរោគឆ្លង ដោយការកាត់បន្ថយនូវការប្រឈមមុខនិងការចំលងមេរោគតាមរយៈឈាមឬសារធាតុរាវសរីរៈក្នុងចំណោមអ្នកជម្ងឺនិងបុគ្គលិកសុខាភិបាល ។ នៅក្រោមគោលការណ៍នៃការប្រុងប្រយត្ន័ជាសកលឈាមឬសារធាតុសរីរៈរាវនៃមនុស្សទាំងអស់ត្រូវបានគិតថា អាចមានឆ្លងមេរោគអេដស៍ ។

### យុទ្ធវិធីចំបងៗ ដើម្បីអនុវត្តគោលនយោបាយទី ៧

អ្នកផ្តល់ប្រឹក្សានិងអ្នកមន្ទីរពិសោធន៍ចាំបាច់ត្រូវអនុវត្តការបង្ការការចំលងមេរោគអេដស៍ដោយអនុវត្តតាមគោលការណ៍ណែនាំស្តីពីការបង្ការជាសកលរបស់ក្រសួងសុខាភិបាល ។

ភ្នំពេញ ខែមករា ឆ្នាំ ២០០៧

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ក្រុមការងារ

ឯកឧត្តម មាន ឈីវុន ប្រធាន មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ

វេជ្ជបណ្ឌិត ព្រហ្ម ផានិត មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ

វេជ្ជបណ្ឌិត  សុខ បញ្ញា  មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ

វេជ្ជបណ្ឌិត  ជា ច័ន្ទកុសលមុនី  មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ